Lynn Public Schools
100 Bennett Street
Lynn, MA 01905
781-477-7220 ext. 3184

អ្នកគ្រប់គ្រងសង្កាត់សាលារង
Kimberlee Powers

# លិខិតផ្ញើជូនឪពុកម្តាយអំពីសៀវភៅតាមដានការសិក្សា

ជូនចំពោះឪពុកម្តាយ និង អាណាព្យាបាលៈ

ឆ្នាំសិក្សាបច្ចុប្បន្ននេះគឺមិនដូចឆ្នាំសិក្សាពីមុនៗនោះទេ។ សម្រាប់កូនរបស់លោកអ្នក ការបង្រៀន និង ការរៀនសូត្រគឺពោរពេញទៅដោយបញ្ហាប្រឈមថ្មីនិងខុសពីមុន។ សិស្សត្រូវពឹងផ្អែកទាំងស្រុងលើបច្ចេកវិជ្ជា និង ប្រព័ន្ធគ្រប់គ្រងការរៀនសូត្រដើម្បីចូលរួមក្នុងការអប់រំរបស់ពួកគេ។ ពួកគេត្រូវបានផ្តាច់ចេញពីគ្រូ និង មិត្តភក្តិរបស់ពួកគេ និង តថភាពថ្មីនៃការអប់រំត្រូវបានដាក់ឲ្យអនុវត្ត។ គោលដៅនៃលិខិតនេះគឺដើម្បីបកស្រាយពីកាលៈទេសៈបច្ចុប្បន្នដែលកំពុងត្រូវបានពិចារណា ខណៈដែលគ្រូកំពុងធ្វើការវាយតម្លៃ និង ដាក់ចំណាត់ថ្នាក់សិស្សនៅក្នុងការរៀនសូត្រពីចម្ងាយ។

គ្រូនឹងដោះស្រាយកិច្ចការនេះ ដោយពិចារណាទៅលើការលំបាកដ៏ធំសម្បើម ដែលសិស្សកំពុងជួបប្រទះ និង ធ្វើការវាយតម្លៃដោយក្តីអនុគ្រោះ និង ទៅតាមកាលៈទេសៈ។ បន្ថែមទៅនឹងការវាយតម្លៃ និង កិច្ចការដែលគ្រូដាក់ឲ្យធ្វើ លក្ខខណ្ឌវិនិច្ឆ័យសំខាន់ផ្សេងទៀតនៅក្នុងការដាក់ចំណាត់ថ្នាក់សិស្សនឹងត្រូវបានយកមកពិចារណា និង រួមមានវត្តមាន ការចូលរួម ការប្រឹងប្រែង និង ការពាក់ព័ន្ធនឹងការងារ។ វាក៏សំខាន់ដើម្បីកត់សម្គាល់ផងដែរថា មិនមែនគ្រប់ព័ត៌មានស្តីពីការដាក់ចំណាត់ថ្នាក់ទាំងអស់មាននិងត្រូវបានរក្សាទុកនៅក្នុងបណ្តាញសង្គម Schoology នោះទេ។ គ្រូនៅទូទាំងសង្កាត់នេះចង់សង្កត់ធ្ងន់ថា វាមានកម្រិតទៅនឹងទិន្នន័យវាយតម្លៃបច្ចុប្បន្នរបស់ពួកគេនៅលើភាពត្រឹមត្រូវ បរិមាណ និង ភាពអាចទុកចិត្តជាទូទៅរបស់វា។ សហគមន៍រៀនសូត្ររបស់យើងបានចាប់ផ្តើមឆ្នាំសិក្សានៅក្នុងស្ថានភាពមិនរឹងប៉ឹងមួយ ដោយមិនមានរបស់គ្រប់យ៉ាងនោះទេ ដែលរួមមានឧបករណ៍ បច្ចេកវិជ្ជា និង ធនធាន។ យើងបានដឹងយ៉ាងច្បាស់ណាស់ថា ស្ថានភាពបច្ចុប្បន្នរបស់យើងគឺមិនដូចគ្នានោះទេ ហើយយើងគួរឆ្លើយតបទៅតាមនេះ។ ការប្តេជ្ញាចិត្តរបស់គ្រូគឺត្រូវផ្តល់ការចង្អុលបង្ហាញដ៏ប្រសើរបំផុតមួយដែលថាកូនរបស់លោកអ្នកបានរៀនសូត្របានកម្រិតណាហើយនៅក្នុងត្រីមាសដំបូងនេះ។

គ្រូចង់សម្តែងការដឹងគុណរបស់ពួកគេនិងការលើកសរសើរដ៏ស្មោះស្ម័គ្ររបស់ខ្លួន ជូនទៅដល់ឪពុកម្តាយ និង ក្រុមគ្រួសារសម្រាប់ការគាំទ្រនិងការយោគយល់របស់លោកអ្នក។ យើងនឹកដល់ការបង្រៀនកូនសិស្សរបស់យើងដោយផ្ទាល់ខ្លាំងណាស់ ប៉ុន្តែនៅតែបន្តប្តេជ្ញាចិត្តដដែលក្នុងការគាំទ្រដល់ការរៀនសូត្រពីចម្ងាយរបស់សិស្ស និង ការបន្តអភិវឌ្ឍទំនាក់ទំនងដ៏កក់ក្តៅនិងយកចិត្តទុកដាក់នៅក្នុងថ្នាក់រៀនរបស់យើង។